00942608

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 01 / 08 / 2013
ម៉ោង (Time/Heure) : 15:06
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E295/1/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣

**ជូនចំពោះ÷** ភាគីនៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក /លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** ចម្លើយតបទៅនឹងសំណើរបស់ ខៀវ សំផន ស្នើសុំការបញ្ជាក់បំភ្លឺ ពាក់ព័ន្ធនឹងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល (ឯកសារ E295/1)

1. កាលពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់អំពីការបែងចែកពេលវេលាសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ដែលរួមមាន ០៨ ថ្ងៃសម្រាប់ការធ្វើសេចក្តីសន្និដ្ឋាន, មួយថ្ងៃសម្រាប់ការជំទាស់ និងរយៈពេលមិនទាន់បញ្ជាក់ច្បាស់លាស់សម្រាប់ជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន (ឯកសារ E288/1/1)។ កាលពីថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីពេលវេលាកំណត់ស្តាពរសម្រាប់សារណាបិទបញ្ចប់ការពិភាក្សាដេញដោល និងកំណត់ពេលវេលាចំនួន ០៩ ថ្ងៃសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល (ឯកសារ E295)។

2. នាពេលបច្ចុប្បន្ន មេធាវីការពារក្តី ខៀវ សំផន ស្នើសុំការបញ្ជាក់បំភ្លឺ ថាតើពេលណាជនជាប់ចោទខៀវ សំផន នឹងត្រូវបានផ្តល់ឱកាសដើម្បីធ្វើសេចក្តីសន្និដ្ឋាន។ ដើម្បីដោះស្រាយសំណើនេះ អង្គជំនុំជម្រះត្រូវការព័ត៌មានបន្ថែម និងបង្គាប់ឱ្យជនជាប់ចោទ ខៀវ សំផន និង នួន ជា ជូនដំណឹងមកអង្គជំនុំជម្រះ ត្រឹមថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៣ អំពីថិរវេលាតាមការប៉ាន់ប្រមាណ ដែលចាំបាច់ដើម្បីធ្វើសេចក្តីសន្និដ្ឋានរៀងៗខ្លួនរបស់ពួកគាត់។ ក្រោយពេលបានទទួលព័ត៌មាននេះ អង្គជំនុំជម្រះនឹងផ្តល់ការគូសបញ្ជាក់បន្ថែមទៅភាគី។

3. នេះជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E295/1។